<u>ការសម្ភាសរបស់លោកពូចាន់រី</u>

១៖អ្នកសម្ភាសគេឈ្មោះថា នួន រៀម ២៖អ្នកដែលត្រូវគេសម្ភាសឈ្មោះថាចាន់ រី

១. បានជម្រាបសួរលោកពូ!

២. បាទៗ!

១. ខ្ញុំចង់សួរឈ្មោះលោកពូឈ្មោះអីដែរលោកពូ?

២. ខ្ញុំឈ្មោះចាន់រី។

១. ចាន់ រី

២. ឈ្មោះសព្វថ្ងៃហ្នឹងមែន?

១. អញ្ចឹងសព្វថ្ងៃហ្នឹងលោកពូឈ្មោះថាចាន់រីត្រូវទេ?

២. បាទ។

១. អញ្ចឹងលោកពូមានឈ្មោះអីផ្សេងហៅក្រៅទេ?

២. អត់មានទេ។

១. អត់មានទេ។

២. បាទ

១. អញ្ចឹងចង់សួរលោកពូថាកាលដែលលោកពូនៅក្មេងតើលោកពូអឺអឺរៀននៅ
សាលាណាដែលលោកពូ?

២. កាលខ្ញុំនៅក្មេងខ្ញុំរៀនបើចាប់ពីរៀនបឋមមកខ្ញុំរៀនដំបូងជាមួយលោក ។

១. បាទបាទ!

២. លោកសង្ឃយើង។

១. បាទ!

២. រៀនខាងកុដលោកដល់ស្រុកវាមានសង្គ្រាមទៅសម័យគេធ្វើរដ្ឋប្រហារខ្ញុំបានមករៀន ភ្នំពេញរៀននៅអឺបឋមសិក្សាទូលស្លែង។

១. បាទៗ! បឋមសិក្សា?

២. ហ្នឹងហើយ! ហើយក្រោយមកក៏ឡើងមករៀនគ្រប់សាលាដែរដល់សាលាបឹងកេង កងសាលាដប់ប្រាំបីមីនានៅក្រុងភ្នំពេញហ្ហ៉ា។

១. បាទៗពូ! អ៉ូ! កាលហ្នឹងពូនៅក្រុងភ្នំពេញ?

២. បាទ!

១. អ៉!

២. ខ្ញុំទៅរៀននៅក្រុងភ្នំពេញហ្នឹង។

១. បាទៗ! អញ្ចឹងពូផ្នែកភាសាតើពូមានចេះប៉ុន្មានភាសាដែរ?

២. ភាសាខ្ញុំអត់ដែលបានធ្លាប់...និយាយទៅខ្ញុំរៀន រៀនបានតិចណាស់អត់បានច្រើនដូចគេហ៉ា ព្រោះតែយើងកើតមកស្គាល់ទាំងសង្គ្រោមរហូត។

១. បាទៗ! ចង់ដឹងថាពូរៀនភាសាខ្មែរ ឥឡូវភាសាខ្មែរពូរៀន អាចចេះឬក៏ចាំបានដូចម្តេចដែរ?

២. ភាសាខ្មែរអាច ខ្ញុំរៀនហ្នឹងខ្ញុំចេះតែភាសាយើងនិងប្រវត្តិអីតិចតួចហ្នឹង។

១. បាទៗ! តើពូរៀនរបៀបដូចជាចងចាំអឺដូចជាឲ្យយើងយល់តាមរបៀបណាតើយើង រៀនផ្ទាល់ខ្លួនឬក៏រៀនគូរឬក៏រៀនជាមួយលោកគ្រូ?

២. ខ្ញុំរៀនពីសម័យហ្នឹងខ្ញុំរៀនគ្ងរផង រៀនជាមួយគ្រូផង ពីសម័យហ្នឹងខ្ញុំបានរៀនមិនមែនតែមួយពេលទេគឺរៀនព្រឹកល្ងាច។

១. បាទៗ! ពីរពេល?

២. បាទ!

១. អញ្ចឹងពូមានស្គាល់មិត្តភក្តិច្រើនអីទេកាលហ្នឹង?

២. កាលហ្នឹងដូចស្គាល់ច្រើនដែរ ប៉ុន្តែឥឡូវវាភ្លេចអស់ហើយ។

១. បាទៗ! ភ្លេចខ្លះ។

២. កាលនៅសិក្សាវាមានហើយពួកម៉ាកមិនចេះអត់ទេ។

១. បាទលោកពូ!

២. មិត្តភក្តិស្គាល់ច្រើនតែយើងបែកអស់រាប់សិបឆ្នាំ អញ្ចឹងហើយមិនដឹងថាអាណាស្លាប់អាណារស់អស់ទៅណា។

១. អញ្ចឹងចង់ដឹងថាពូស្គាល់មិត្តភក្តិជិតស្និតហើយមិត្តភក្តិជិតស្និទ្ធពូបំផុតឈ្មោះអីដែរ?

២. ជិតស្និត បើចាំឈ្មោះខ្ញុំក៏ភ្លេចដែរ។

១. អត់អីទេលោកពូ។

២. បាទ!

១. អញ្ចឹងចង់ដឹងថាលោកពូស្រុកកំណើតកើតនៅឯណាដែរលោកពូ?

២. ស្រុកកំនើតខ្ញុំកើតនៅឧត្តុង។

១. នៅប្រទេសកម្ពុជា?

២. នៅប្រទេសកម្ពុជា។

១. ខេត្តណាពូ?

២. ខេត្តកំពង់ស្ពឺ។

១. បាទៗ! អញ្ចឹងពូចាំទេភូមិពូ?

២. អត់ចាំទេភូមិ។

១. បាទៗហើយចុះក្រុងពូ?

២. បើកើតលឺតាមម្តាយខ្ញុំហ្នឹងគាត់និយាយតែដល់ពេលដឹងក្តីមកគឺនៅទីក្រុងភ្នំពេញ។

១. អ៎! បាទៗ! អញ្ចឹងធំដឹងក្តីនៅទីក្រុងភ្នំពេញ?

២. ព្រោះគ្រួសារខ្ញុំគាត់មានធ្វើការងាររាជការអញ្ចឹងហើយទីតាំងអត់មាននៅមួយកន្លែងទេតិចគេផ្លាស់ទៅណេះទៅណោះអញ្ចឹងទៅណាស់។

១. ផ្លាស់រហូត អញ្ជឹងអត់ចាំកន្លែង?

២. គ្មានគោលដៅនៅមួយកន្លែង តែបើចាំកន្លែងជាងគេគឺនៅទីក្រុងភ្នំពេញហ្នឹងម្តង។

១. នៅទីក្រុងភ្នំពេញបាទ ហើយអឺអញ្ចឹងចង់សួរពូថានៅឆ្នាំនេះតើពូមានអាយុប៉ុន្មានហើយ?

២. ឆ្នាំនេះមើលខ្ញុំកើតនៅឆ្នាំ១៩៦២មកដល់ឥឡូវ...

១. ពូអាយុប៉ុន្មានឥឡូវ? ឥឡូវពូអាយុប៉ុន្មានដែរមានចាំទេ?

២. ដូចជា៥៥ហើយហ្ន៎?

១. ពូឥឡូវអាយុ៥៥ចុះក្នុងសៀវភៅគ្រួសារពូដាក់ហ៊ាប៉ុន្មានដូចជាអត្តញ្ញាណប័ណ្ណអីពូ?

២. អត្តញ្ញាណប័ណ្ណគេអត់មានដាក់អាយុយើងទេគេដាក់តែឆ្នាំកំនើតដែលយើងកើតនៅថ្ងៃណា ខែណាឆ្នាំណាអីតែប៉ុនហ្នឹងទេ។

១. ហើយអាយុពូដូចជា៥៥ម៉ែនទេពូ?

២. ហ្នឹងហើយ។

១. បាទពូ។

២. បើយើងដកទៅយើញហើយដក២០១៧ដក១៩៦២មកយើញហើយអាយុ។

១. បាទ!

ពូប្រហែលជា៥៥ឆ្នាំអញ្ចឹងអឺចង់ដឹងថាលោកពូការរៀបការពូរៀបការនៅពេលណាដែរ?

ពូចាំថ្ងៃខែឆ្នាំកំនើតដែរទេពូ ថ្ងៃខែកំនើតដែលពូបានរៀបការជាមួយអ៊ី(មីង)?

២. ដូចមិនចាំទេយូរហើយ។

១. យូរហើយ?

២. យូរហើយ អត់ចាំ! គ្រាន់តែថាកាលពីពេលរៀបអាពាហ៍ពិពាហ៍ហ្នឹងដឹងថាខ្ញុំហ្នឹងមានអាយុ ប្រហែល២៧ប៉ុន្តែក្នុងឆ្នាំ បើមិន៨៦, ៨៧កាលហ្នឹង។

១. ៨៦ទៅ៨៧?

២. ហ្នឹងហើយ។

១. ច្បាស់ហើយលោកពូ?

២. ហ្នឹងហើយប្រហែលជាពីរឆ្នាំហ្នឹងឯង។

១. បាទៗ!

២. មិនលើសពីហ្នឹង បើមិន៨៦ទេ៨៧។

១.	បាទអញ្ចឹងអឺពូអាយុប៉ុន្មានដែរ? ហើយអ៊ីុអាយុប៉ុន្មាន?

២.	២៧។

១.	២៧!ចុះអ៊ី? ២២? គាត់ប្រាប់ថា២២មែនហ្ន៎? ហើយខ្ញុំចង់ដឹងថាតើពូមានទំនាក់ទំនងជាមួយអ៊ីតាមរយៈណា តាមរបៀបណា?

២.	ខ្ញុំដែលទាក់ទងគ្នានៅធ្វើការងារជាមួយគ្នា។

១.	បាទៗ!

២.	ធ្វើការរោងចក្រ រោងចក្រខ្ចៅដូនទាវយើងហ្នឹង។

១. អ៉ូ! នៅបាត់ដំបងយើង?

២. បាទ!

១.	អ៉ូ! អញ្ចឹងអឺពូមានទំនាក់ទំនងជាមួយអ៊ីហ្នឹងរយៈពេលប៉ុន្មានបានយើងបានដល់ថ្នាក់ស្គាល់គ្នា ឬមួយជិតជិតឬមួយក៏ដល់ថ្នាក់មានការរៀបចំខាងអ៊ីដូចជាការភ្ជាប់ការរៀបអាពាហ៍ពិពាហ៍?

២.	លឿនដែរអត់ដល់មួយឆ្នាំផងប្រហែងជាប៉ុន្មានខែ ពីរបីខែប៉ុណ្ណឹងឯង។

១.	ពីរបីខែ លឿន។

២.	ហ្នឹងហើយរហ័ស! កាលហ្នឹងវាច្រើនពេកកញ្ជក់ខ្ញុំយកទៅមុនទៅគាត់លឿនជាងគេ។

១.	កាលហ្នឹងពូមានស្ថានភាពពិបាកអីទេពេលដែលតាមស្រលាញ់អ៊ីមានឧបសគ្គផ្សេងទៀតទេ?

២.	អត់មានឧបសគ្គអីរាវាំងទេ។

១.	ពេលចិត្តគាត់ហើយឲ្យពុកម៉ែទៅស្តីដណ្តឹងបណ្តោយ
អញ្ចឹងតាមគាត់រយៈពេលប៉ុន្មានទើបឈានដល់ ថ្នាក់រៀបចំអាពាហ៍ពិពាហ៍ពូ?

២.	ប៉ុន្មានថ្ងៃប៉ុន្មានខែហ្នឹងហ្ន៎?

១.	បាទៗប៉ុន្មានថ្ងៃអីដូចជាប៉ុន្មានខែដូចជារហូតដល់ថ្ងៃមួយមានអាពាហ៍ពិពាហ៍រយៈពេលដែលពូស្រលាញ់អ៊ីមកដល់ពេលរៀបការចង់ដឹងថាប៉ុន្មានខែប៉ុន្មានថ្ងៃដែរ?

២.	ជិតកន្លះឆ្នាំ ថាកន្លះឆ្នាំចុះ។

១.	អឺប្រាំមួយខែ?

២.	ប្រាំមួយខែ។

១.	ប្រហែលកន្លះឆ្នាំ។ អញ្ចឹងខ្ញុំបង្វៃរមកពី ចង់សួរពីប្អូនស្រី បងប្អូនប្រុសស្រីពូមានប៉ុន្មានអ្នកដែរ?

២.	បង្កើតហ្ន៎?

១.	បាទ បងប្អូនបង្កើត។

២.	បងប្អូនបង្កើតមានតែម្នាក់ តាំងពីសម័យប៉ុលពតបែកគ្នាមកសល់ពីរនាក់ទេមួយសម្បុក។

១.	សល់ពីរនាក់ហើយចឹងប្រុសពូម្នាក់ឯងនិងម្នាក់នាក់ទៀតប្រុសដែរមែនហ្ន៎?

២.	ទេស្រី។

១.	អ៎ ស្រី! ចុះប្អូនហ្ន៎ពូ?

២.	ប្អូន។

១.	ប្អូនស្រី ហើយនិងពូ?

២.	ប្អូនស្រីពៅគេហើយនិងខ្ញុំ កណ្តាល។

១.	ពូកូនទីពូកូនទីប៉ុន្មានពូកូនទីមួយឬក៏...?

២.	ខ្ញុំ...

១.	កូនទីមួយព្រោះគាត់ប្អូន?

២.	អត់ទេអឺបើនិយាយបងប្អូនទាំងអស់ហ្ហ?

១.	អត់ទេនិយាយ...

២.	បងប្អូនដែលសល់ហ្នឹងហ្ហ?

១.	អត់ទេ បងប្អូនទាំងអស់មាន២នាក់។

២.	បងប្អូនបើទាំងអស់កុំស្លាប់វាមាន៧។

១.	អ៎ ៧នាក់!

២.	ហ្នឹងហើយ!

១.	ក៏ប៉ុន្តែសល់ពីរ?

២.	សល់តែ២ទេ។

១.	អញ្ចឹងចង់ដឹងថាតើពូកូនទីប៉ុន្មានដែរ?

២.	ខ្ញុំកូនទីបួន។

១.	កូនទីបួន អញ្ចឹងមានន័យថាមានបងបីនាក់។

២.	ហ្នឹងហើយ!

១.	បាទតែឥឡូវគាត់ស្លាប់តាំងពីជំនាន់ហ្នឹងមកសល់តែពីរនាក់ ឥឡូវពូអឺ...បែកពីគាត់ហើយសល់ ឥឡូវសល់ពូម្នាក់ឯង។

(ប្រពន្ធ)៖ ពួកគាត់ស្លាប់ដោយសារតែគេវាយចោលនិងអត់បាយ។

១. អ៉ូ វេទនាមែនទែន! តែឥឡូវហ្នឹងវាម៉េចបច្ចុប្បន្នវាដូចពួរកអត់ឃើញទេ?

២. អត់!

១. អត់ឃើញសោះ?

(ប្រពន្ធ)៖ នឹកដែរ តែគាត់នឹក ពេលណានឹកគាត់ទឹកភ្នែក។

១. បាទ។! ហើយអោយតែនឹករឿងហ្នឹងពួមានអារម្មណ៍ថាចង់នឹកស្រក់ទឹកភ្នែក។

(ប្រពន្ធ)៖ គាត់និយាយលែងរួច។

១. សុំទោសពូ!

(ប្រពន្ធ)៖ គាត់នឹកឃើញបងប្អូន។

១. បាទ។! ហ្នឹងហើយគាត់អត់ចង់...

(ប្រពន្ធ)៖ គាត់អូលដើមក និយាយលែងចេញ។

១. អឺមានទៀតចង់សួរថា អឺពួមានចាំ...សុំទោស! អត់អីទេពូ ពួតាំងចិត្តតិច។

(ប្រពន្ធ)៖ គាត់និយាយរឿងហ្នឹងគាត់នឹកឃើញ បងគាត់គេយកវាយចោល។

១. បាទ។!

(ប្រពន្ធ)៖ ប៉ាគាត់គេជំនាន់ទម្លាក់រដ្ឋប្រហារបែករហូត។

១. បាទ។!

(ប្រពន្ធ)៖ ដល់ពេលម្តាយប៉ុល ពតសម្លាប់ចោលទាំងអស់ នៅម្នាក់ឯងដល់ពេលមាន២នាក់បងប្អូន ពេលគ្រាប់ផ្លោងតោងបងប្អូន ដឹកដៃបងប្អូនរត់ហ្ការ។

១. បាទ!

(ប្រពន្ធ)៖ សុខចិត្តលើកប្អូនបីទៅឆ្លងប្រលាយ

១. បាទ បាទ!

(ប្រពន្ធ)៖ ចា៎! ឆ្លងប្រលាយហើយ ងាកមកយកអង្ករ គ្រាប់ផ្លោងចំពាក់កណ្តាលបែកគ្នាបណ្តាយ។

១. អ៊ូ!

(ប្រពន្ធ)៖ ចា៎ បែកប្អូនស្រីមកទល់ឥឡូវ។

១. បែកបាក់កម្សត់មែនទែន និយាយទៅ។

(ប្រពន្ធ)៖ អញ្ជឹងទៅក៏គាត់និយាយអត់រួច។

១. អត់រួច បាទ! ខ្ញុំយល់អារម្មណ៍គាត់ដែរ។

(ប្រពន្ធ)៖ ចា៎! រាល់ថ្ងៃនឹកប្អូនណាស់ នឹកប្អូន នឹកម្តាយ គាត់នឹកទាំងអស់។ គាត់ថានៅតែប្អូនស្រីមួយ បើសិនជាបានជួបប្អូនស្រី គាត់មិនដឹងអរយ៉ាងណា បើសិននៅដល់ឥឡូវសែជាងហើយ។

១. បាទៗអ៊ីៗ!

(ប្រពន្ធ)៖ ពេលហ្នឹងបែកគ្រាប់ផ្លោង យើងមិនដឹងថាស្លាប់ឬរស់
ហើយគាត់នៅចាំថាមនុស្សស្រីម្នាក់ដឹក ដៃប្អូនគាត់រត់អញ្ជឹងហ្នា៎។

១. បាទៗ!

(ប្រពន្ធ)៖ ចុះបើវាផ្លោងពាក់កណ្តាលហើយ។

១. បាទ!

(ប្រពន្ធ)៖ យើងដឹងវាស្លាប់ឬរស់ យើងក៏វាមិនដឹងយើងស្លាប់រស់។

១.	បាទ!

(ប្រពន្ធ)៖ ចា៎!

១.	តាមមើលទៅវាអឺ ជីវប្រវត្តិគាត់វាបែកចឹង បងប្អូនគាត់ច្រើនចឹងវាបែកទៅអស់បណ្តាយ អញ្ចឹងមានន័យថាលោកពូនៅសល់តែប្អូនប្រុសម្នាក់ឥឡូវគាត់បែកទៅទៀត...

(ប្រពន្ធ)៖ ស្រី

១.	អ៎ូ ប្អូនស្រី ស្រីពៅ។ បាទៗពូ! ចង់សួរពូ...

(ប្រពន្ធ)៖ ស្លាប់ហ្នឹងគេយកទៅកប់មិនតែឯង និយាយមួយរណ្តៅមិនចេះតិចនាក់។

១.	អ៎ូ បាទ!

(ប្រពន្ធ)៖ ស្លាប់ក្នុងពេទ្យ មិនទាន់ម្តាយផង គេរុំកន្ទេលយកទៅបាត់

១.	អ៎ូ!

(ប្រពន្ធ)៖ ហើយគេតាមរកគាត់ យកគាត់វាយចោលទៀត តែមានប្រធានគេមួយ យុវជនគេជួយ សុំនៅជាមួយបានរស់តែឯង។

១.	បាទៗពូ! សុំទោស! ចង់សួរពូមាននៅចាំថ្ងៃខែឆ្នាំកំនើតរបស់ឪពុកម្តាយរបស់ពូទេពូ?

២.	អត់ចាំទេ។

១.	បាទអាយុគាត់ប៉ុន្មានក៏អត់ដឹងដែរពូហ្ន៎?

២.	អត់ អត់ដឹង។

(ប្រពន្ធ)៖ គាត់ចាំឈ្មោះឪពុកម្តាយបង្កើតគាត់ គាត់ចាំឈ្មោះ។

១.	បាទៗ!

(ប្រពន្ធ)៖ ឈ្មោះឌីពុកគាត់ហ្នឹង សៅ សុខន។

១. សៅ សុខន ឌីពុកគាត់ ចុះម្តាយពូ?

(ប្រពន្ធ)៖ ម្តាយគាត់ឈ្មោះហុង សាលី។

១. ហុង សាលី បាទ ប៉ុន្តែឆ្នាំកំណើតគាត់ពិបាកចាំតិច?

(ប្រពន្ធ)៖ អត់ចាំទេ។

១. បាទព្រោះវាយូរហើយ វាយូរហើយ។ ចុះ....

(ប្រពន្ធ)៖ គាត់ទាហានអូនអើយ មិននៅរស់។

១. អ៉ូ! ជំនាន់ទាហានអញ្ចឹងមានន៍យថាទាហានហ្នឹងវាពេញ...

(ប្រពន្ធ)៖ គាត់សក្តីប្រាំទៀតហ្ហ៉ា ធ្វើម៉េចគេទុក។

១. អត់ទុកបានទេព្រោះថាទាហានវាចាំបាច់ទោសធ្ងន់បំផុតសម័យណុង។

(ប្រពន្ធ)៖ ដាក់អាម៉ារីនទៅ ដឹងយកទៅចាក់ចោលនៅណា។

១. បាទៗ!

(ប្រពន្ធ)៖ បាត់រហូត! គាត់ស្រម៉ៃយើញគេ...

២. មែនទាហានទេអូនអើយក្នុងក្រសួងការងារយើងសព្វថ្ងៃហ្នឹងគាត់នៅក្នុងក្រសួងមហាផ្ទៃ។

១. មហាផ្ទៃ!

២. ហ្នឹងហើយ!

១. បាទអាហ្នឹងក៏ទាក់ទងដូចជា...

២. វាដូចតែគ្នា កាន់អាវុធដូចគ្នា។

១.	បាទ។បាទជាសត្រូវទី១របស់ពួកខ្មែរក្រហមហ្នឹងគឺទាហានហ្នឹងឯង	យោធា
អញ្ជឹងមានន័យថាបើ ប្តូរស្ថានភាពដូចជា	ធ្វើជាមនុស្សធម្មតាថ្ងៃហ្នឹងដូចជាពួអត់
អត់ដល់គេសម្លាប់ទេមែនទេ?

(ប្រពន្ធ)៖ បាត់ខ្លួនបណ្តោយ មិនដឹងគេសម្លាប់មិនសម្លាប់គេហៅឡើងអាម៉ារីន ឡើងទាំងអស់គ្នា។

១.	មេគេហៅឡើងទាំងអស់។

(ប្រពន្ធ)៖ ចា!

១.	ហើយបើសម័យហ្នឹង បើ...

២.	មិនមែនទេពីសម័យហ្នឹងឯខ្ញុំនៅដឹងក្តីហើយខ្ញុំនៅចាំហ្ហា។

១.	បាទៗ!

២.	សម័យទម្លាក់រដ្ឋប្រហារហ្នឹងគេប្តូរប៉ាខ្ញុំដកចេញពីអឺខេត្តកំពង់ស្ពឺ ហ្នឹងអោយទៅកាន់នៅខេត្ត
ក្រចេះស្រុកឆ្លូង។

១.	បាទៗ គេប្តូគាត់ទៅវិញទៅ។

២.	ដល់តែពេលហ្នឹងខ្ញុំនៅចាំ។

១.	បាទៗ!

២.	ពេលហ្នឹងហើយដែលយើងសង្គ្រាមជាមួយនិងវៀតណាមខាងជើងពួកធ្មេញខ្មៅហ្ហា

១.	បាទៗ!

២.	ខ្ញុំមិនដឹងខាងជើងខាងត្បូងទេព្រោះដឹងតែថាធ្មេញខ្មៅវាចេះតែមានការរកាំរកុះៗអញ្ចឹង
ទៅដល់តែគេធ្វើរដ្ឋប្រហារទម្លាក់សម្តេចហ្នឹងបានមកដល់សម័យសាធារណរដ្ឋលន់នល់គាត់

នធ្វើរដ្ឋប្រហារហ្នឹងគាត់ក៏បាត់ខ្លួនទៅនៅខេត្តក្រចេះ ស្រុកឆ្លងមុននឹងគាត់នៅហ្នឹងគាត់អោយអឺ កាលហ្នឹង គាត់អោយម្តាយខ្ញុំនាំកូនមករៀននៅភ្នំពេញវិញ មក។

១. បាទៗ!

២. ហើយចាំគាត់មកតាមក្រោយអញ្ចឹងហ្លា។

១. បាទ! ពូខ្ញុំចង់សួរពូមួយថា តើពូមាននៅចាំជីដូនជីតាពូគាត់នៅអាយុប៉ុន្មានកាលពីជំនាន់ហ្នឹងពូ?

២. មិនចាំទេ។

១. បាទ

២. ពុកម្តាយមិនចាំផងទម្រាំជីដូនជីតាទៀត។

១. ចុះកន្លែងដែលពួកគាត់កើតពូមានចាំទេពូ? ដូចជាស្រុកកំណើតគាត់?

២. ស្រុកកំនើតគាត់កាលហ្នឹង ខ្ញុំដឹងក្តីមកខ្ញុំលឺយាយតាខ្ញុំនិយាយកាត់នៅខាង ខាងហ្នឹងមិនដឹងខេត្តកណ្តាល ឬក៏ខេត្តអីទេ នៅព្រៃកដូង។

១. ព្រៃកដូង។

២. ព្រៃកដូង ត្រើយស្លាយើងនៅខាងស្អាងហ្នឹងហ្លា។

១. បាទៗ!អាហ្នឹងស្រុកឬមួយក៏...?

២. អាហ្នឹងដូចជាភូមិយុំទេអី ភូមិព្រៃកដូង ព្រៃកដូង ត្រើយស្លា។

១. បាទអាហ្នឹងនៅខេត្តណា នៅខេត្តណាអាហ្នឹង?

២. អាហ្នឹងដូចខេត្តកណ្តាល។

១. ខេត្តកណ្តាល។

២.	នៅត្រើយខាងកើតទន្លេ។

១.	កើតទន្លេ បាទ! ក្រុងណាពូមាននៅចាំទេពូ? ក្រុងភ្នំពេញ?

២.	ខេត្តកណ្តាល ក្រុងភ្នំពេញហ្ន៎?

១.	បាទ!

២.	ពីសម័យហ្នឹងមិនដឹងថាក្រុងណាខេត្តណា?

១.	ព្រោះវាយូរហើយជំនាន់ហ្នឹង ។

២.	ខ្ញុំមិនដឹង ព្រោះសម័យហ្នឹង..

១. គាត់ខ្ជិចអស់ហើយ។

១.	នៅប្រទេសកម្ពុជា?

២.	នៅប្រទេសខកម្ពុជាយើង ប្រទេសខ្មែរក៏បាន។

១.	កម្មរហូតបាទ។

(ប្រពន្ធ)៖ ព្រោះអីកម្មនៅមុខ។

១.	កម្មរហូតម្តងកម្ពុជា! ចង់សួរពូថាតើពូមានដឹងអ្វីផ្សេងទៀតទេពីក្រុមគ្រួសាររបស់ពូ។

២.	បើនិយាយពីដឹងច្រើន។

១.	បាទ! ពូអាចសង្ខេបបានទេ? ដូចជារឿងក្រុមគ្រួសារបស់ពូពីមុនមកអំពីក្រុមគ្រួសារ ពីមុនមកក្រុមគ្រួសារដូចជាឪពុកម្តាយរស់នៅជាមួយគ្នាពីមុនមក?

២.	ដូចអត់មានអីផងគ្រួសារខ្ញុំរស់នៅស្រួលដល់ពេលសម័យសង្គ្រាម យើងម៉េចស្រួល។

១.	កាលពូនៅហ្នឹងមានជីវភាពម៉េចដែរ? ដូចជាជីវភាពរបស់ពូនេះយ៉ាងម៉េចដែរ? ធ្ងរធារ?

២. មានស្អី ជីវភាពខ្ញុំធូរធារពីសម័យហ្នឹងអត់មានអីលំបាកផង។

១. បាទៗ! អញ្ចឹងមានន័យថាពួកគាត់គឺនៅក្នុងប្រទេសកម្ពុជាយើងទាំងអស់មែនទេពូ?

២. នៅប្រទេសកម្ពុជា

១. គិតថាមានរស់នៅឯបរទេសអីទេ?

២. អត់ទេ អត់មានទេ!

១. បាទៗ! តើពួកគាត់រស់នៅខេត្តណាពូនៅជួបជុំគ្រួសារពូ?

២. នៅក្រុងភ្នំពេញ។

១. អ៎! នៅក្រុងភ្នំពេញ តើពួកគាត់ធ្លាប់រស់នៅក្រៅប្រទេសទេពូ?

២. អត់ទេ!

១. អត់ទេ។

២. អត់ដែលមានរស់នៅក្រៅប្រទេសទេ។

១. ឥឡូវខ្ញុំសូមបញ្ចប់ត្រឹមហ្នឹង។ អរគុណពូច្រើន ដែលបានរៀបរាប់ឲ្យខ្ញុំដឹងទាំងអស់ពីជីវ ប្រវត្តិ របស់ពូ។